# GC ការពារក្រេឌីតជាក្រុម



## តើអ្វីទៅជា GC ការពារក្រេឌីតជាក្រុម?

GC ការពារក្រេឌីតជាក្រុម គឺជាគម្រោងធានារ៉ាប់រងអាយុជីវិតជាក្រុម ដែលផ្តល់ការធានាលើប្រាក់កម្ចី ក្នុងករណីដែលអ្នកខ្ចីប្រាក់ ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។ គម្រោងនេះការពារគ្រឹះស្ថានហិរញ្ញវត្ថុពីហានិភ័យនៃការបាត់បង់ មូលនិធិ និងការពារក្រុមគ្រួសាររបស់អ្នកខ្ចីប្រាក់ពីបំណុលដែល មិនបានគ្រោងទុក។

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុសមាជិកដែលត្រូវបានធានា | ចាប់ពី 18 ដល់ 64ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1 - 30ឆ្នាំ |
| វិធីសាស្ត្របង់បុព្វលាភ | បង់ម្តងផ្តាច់ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $1,000ឡើង |
| ប្រភេទនៃទឹកប្រាក់ត្រូវបានធានា | ប្រភេទថេរ ឬប្រភេទថយចុះ * |

*ប្រភេទថេរ មានន័យថាទឹកប្រាក់ត្រូវបានធានានៅរក្សាចំនួន ថេរដដែលក្នុងអំឡុងពេលធានារ៉ាប់រង។
ប្រភេទថយចុះ មានន័យថាទឹកប្រាក់ត្រូវបានធានានឹងត្រូវថយចុះ ជារៀងរាល់ខែ ឬជារៀងរាល់ឆ្នាំនៅថ្ងៃខួបនៃការធានារ៉ាប់រងរបស់ សមាជិកដែលត្រូវបានធានា។ សំណងមរណភាព និងពិការភាព ទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលត្រូវផ្តល់ជូនគឺស្មើនឹង១០០%នៃ ទឹកប្រាក់ត្រូវបានធានានៅគ្រានោះ។

# អត្ថប្រយោជន៍ធានារ៉ាប់រង

**សំណងមរណភាព**
100% នៃទឹកប្រាក់ត្រូវបានធានា

**សំណងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**
100% នៃទឹកប្រាក់ត្រូវបានធានា

# ករណីមិនធានា

**១. មរណភាព**
(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃសមាជិកដែលត្រូវបានធានា។
(២) ការប្រព្រឹត្តិ ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។
(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លោចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬផលវិបាកផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**
(១) សង្គ្រាម សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាព ប្រឆាំងនឹងរដ្ឋាភិបាលនិងអំពើភេរវកម្ម។
(២) ខណៈពេលដែលសមាជិកដែលត្រូវបានធានាប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលសមាជិកដែលត្រូវបានធានាកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។
(៣) ស្ថានភាពដែលមានពីមុនស្រាប់មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលសមាជិកដែលត្រូវបានធានាបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។
(៤) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

ករណីមិនធានាទាំងនេះ គឺជាចំនុចសំខាន់ខ្លះៗប៉ុណ្ណោះ។ សម្រាប់ករណីមិនធានាលម្អិតទាំងស្រុង សូមពិនិត្យមើល ៩ និងលក្ខខណ្ឌធានារ៉ាប់រង។

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌជានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌជានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

អគារ C ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ